# សូមរំលឹកអំពីកំណត់ត្រាម៉ោងធ្វើការ

## សម្រាប់បុគ្គលិកមើលថែតាមផ្ទះ និងអ្នកមើលថែផ្ទាល់ខ្លួន

- ដើម្បីប្រាកដថាម៉ោងធ្វើការត្រូវបានកត់ត្រាត្រឹមត្រូវ និងទាន់ពេលវេលា បុគ្គលិកមើលថែតាមផ្ទះ និងអ្នកមើលថែផ្ទាល់ខ្លួនត្រូវតែវាយបញ្ចូលម៉ោងធ្វើការរបស់ខ្លួនទៅក្នុងប្រព័ន្ធ OR PTC DCI ។
- សូមប្រើវិធីសាស្ត្រចុះម៉ោងធ្វើការក្នុងពេលដែលអ្នកកំពុងធ្វើការ (តាមកម្មវិធីក្នុងទូរសព្ទដៃ តាមខ្សែទូរសព្ទ ឬ ប្រអប់ Fob) គ្រប់ពេលតាមដែលអាចធ្វើទៅបាន។
- សូមកុំយកក្រដាសដែលសរសេរម៉ោងធ្វើការ ទៅដាក់នៅក្នុងការិយាល័យក្រសួងសម្រាប់អោយបុគ្គលិកជួយដំណើរការ។ បុគ្គលិកមិនអាចវាយបញ្ចូលម៉ោងធ្វើការរបស់អ្នកផ្តល់សេវាមើលថែបានទេ។
- បុគ្គលិកមើលថែតាមផ្ទះ និងអ្នកមើលថែផ្ទាល់ខ្លួនប្រហែលជាអាចប្រើកុំព្យូទ័រដែលមាននៅក្នុងសាលទទួលភ្ញៀវ ដើម្បីវាយបញ្ចូលម៉ោងធ្វីការ ឬវាយម៉ោងធ្វើការទៅក្នុងវិបផតថល OR PTC DCI ។

---

ជំនួយ និងព័ត៏មានបន្ថែមអាចរកបាននៅលើគេហទំព័រ OR PTC DCI នៅ៖ PTC.Oregon.gov ដោយចុចលើផ្នែក “Learning Materials”។

**សម្រាប់ជំនួយក្នុងការចុចចូលគណនី និងសំណួរពីប្រព័ន្ធជាមូលដ្ឋានតែប៉ុណ្ណោះ៖** សូមទាក់ទងទៅ DCI Help Desk៖ តាមទូរស័ព្ទ លេខ 855-565-0155 ឬ អ៊ីមែល ORPTCSupport@dcisoftware.com។

**បុគ្គលិកមើលថែតាមផ្ទះ៖** ចូរនិយាយជាមួយបុគ្គលិកការិយាល័យ ODHS ក្នុងតំបន់ ប្រសិនបើអ្នកមានសំណួរអំពីផែនការសេវាកម្ម ភារកិច្ច ម៉ោងដែលបានអនុញ្ញាត គោលការណ៍ ឬធ្វើបច្ចុប្បន្នភាពព័ត៏មានទំនាក់ទំនង ។

**អ្នកមើលថែផ្ទាល់ខ្លួន៖** ចូរទាក់ទងទៅកម្មវិធី PCA ដើម្បីទទួលបានជំនួយក្នុងការកែតម្រូវម៉ោងធ្វើការ ឬបញ្ហាប្រាក់ឈ្នួល។ ទូរស័ព្ទទៅលេខ 888-416-3184 ឬអ៊ីមែលទៅ PC.20@odhsoha.oregon.gov ។ សម្រាប់សំណួរអំពីម៉ោងដែលបានអនុញ្ញាត ឬដើម្បីធ្វើបច្ចុប្បន្នភាពព័ត៏មានទំនាក់ទំនង សូមទូរស័ព្ទទៅ Comagine តាមលេខ 888-416-3184 ឬអ៊ីមែល ORBHSupport@comagine.org ។